**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៦២ សសរ**

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការសម្រាប់គម្រោងប្រព័ន្ធទូរគមនាគមន៍**
**សម្រាប់វិស័យការពារជាតិ និងសន្តិសុខជាតិ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ**
**ហិរញ្ញប្បទានរវាង**
**សាធារណរដ្ឋប្រជាមានិតចិនជាមួយព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៤.អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ ១ :** បង្កើតគណៈកម្មការសម្រាប់គម្រោងប្រព័ន្ធទូរគមនាគមន៍ សម្រាប់វិស័យការពារជាតិ និងសន្តិសុខជាតិ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានរវាងសាធារណរដ្ឋប្រជាមានិតចិនជាមួយព្រះរាជាណាចក្រកម្ពុជា ។

www.pheakdeylaw.com

**ប្រការ ២ :** គណៈកម្មការនេះមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២- ក្រសួងការពារជាតិ | សមាជិក |
| ៣- ក្រសួងមហាផ្ទៃ | សមាជិក |
| ៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ៣ :** គណៈកម្មការនេះមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

-ដឹកនាំ សម្របសម្រួលលើការងាររៀបចំ និងដំណើរការអនុវត្តគម្រោងឲ្យទទួលបានជោគជ័យ។

-ពិនិត្យ សម្រេចលើលក្ខណៈបច្ចេកទេស តម្លៃ និងការអនុវត្តនីតិវិធីនានាសម្រាប់អនុវត្តគម្រោង រួមទាំងការចុះហត្ថលេខាលើកិច្ចសន្យាពាក់ព័ន្ធនានារបស់គម្រោង។

-ក្នុងករណីត្រូវចាត់វិធានការលើសពីសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការអាចសហការ ឬស្នើអោយមានកិច្ចសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍តាមតម្រូវការចាំបាច់ជាក់ស្តែង។

**ប្រការ ៤ :** គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ៥ :** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ៨ ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>ចម្លងជូន:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
 នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់
 ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ដូចប្រការ ២
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com